

# កញ្ចាញ់ចេកសម្លម

# Sat Dich

Sorn Srey Neang

Let's Read
The Asia Foundation



នៅក្នុងគុម្ពត្រាវ មានកញ្ចាញ់ចេកមួយហ្វូងកំពុងលោតលេង ចុះឡើងៗ ស្រែកច្រៀងឡេឡឡាន់ឮទ្រហឹងអឺងកង។ ប៉ុន្តែ មានកូនកញ្ចាញ់ចេកមួយក្បាលចម្លែកខុសពីគេរូបរាងពពាល ចម្រុះពណ៌ នៅសំងំលេងតែឯង។ អាល្អិតនេះ គិតតែលេង ឥតប្រយោជន៍ មិនដែលជួយការងារម្ដាយឡើយ។



រំពេចនោះ ពោះកូរព្ទស្ទូរតែគ្រូកៗ! វាស្រែកឡើងផ្អើលគេផ្អើលឯង៖ ”ម៉ែ! ម៉ែ! ចូកចូកឃ្លានខ្លាំងណាស់! ឃ្លានទៀតហើយ!”



ចូកចូករត់ទៅផ្ទះយ៉ាងលឿន រត់ផង ដួលផង។ ផ្គរលាន់ខ្លាំងៗ! វាភ័យឡើងញ័រខ្លួន រហូតលេចនោមច្រូចៗ! ដួលទៀតហើយ មើលចុះន៎ ចូកចូករមៀលដូចបាល់អីចឹង ។



ពេលទៅដល់ផ្ទះ វាសួរទាំងឆ្ងល់ថា៖     ម៉ែៗ! ម៉ែកើតអីហ្នឹង?”
ម្ដាយនិយាយតិចៗ៖ ”ចូកចូក! ឥឡូវម៉ែឡើងកន្ទួលរមាស់ ក្ដៅពេញខ្លួន ក្រោកលែងរួចហើយ!”
ចូកចូក សួរបន្ត៖ ”តើម៉ែឆ្លងជំបៅនេះមកពីណា?”
ម្ដាយរៀបរាប់៖ ”ព្រឹកមិញ ម៉ែចេញទៅរកចំណីឱ្យកូនឆី ក៏រអិលធ្លាក់ចូលក្នុងលូទឹកស្អុយ។”

ចូកចូកយកដៃជូតទឹកភ្នែក៖ ”ហិហិហិ! ដោយសារតែកូន ទើបម៉ែទៅជាបែបនេះ! កូននឹងរកថ្នាំព្យាបាលម៉ែ!”
”ទេៗ! ភ្នំនោះនៅឆ្ងាយណាស់ ហើយត្រូវឆ្លងដៃទន្លេទៀត!”

"សូមម៉ែកុំព្រួយ! ខ្ញុំនឹងទៅបេះថ្នាំឱ្យបាន ម៉ែទ្រាំបន្តិចទៅ!"



ចូកចូកធ្វើដំណើរលេចវាលចូលព្រៃ លេចព្រៃចូលវាល ក៏ដល់ដៃទន្លេមួយ។ វាមុខស្អុយ អង្គុយសំកុកទាំងអស់សង្ឃឹម "តើឆ្លងម៉េចកើតទៅ? ធំណាស់លោកអើយ!"



រំពេចនោះ វាឃើញសម្បកកំប៉ុងជ័រមួយអណ្តែតភ្លឹបភ្លែតៗក្បែរ មាត់ច្រាំង រួចបើកភ្នែកធំៗ សើចហាសហាំ! ចូកចូកពិតជាឈ្លាសវៃណាស់ វាបានច្នៃកំប៉ុងជ័រនោះធ្វើជាទូកដ៏ស្រស់ស្អាត។



ជិះដល់ពាក់កណ្ដាល វាជួបនឹងត្រីមួយហ្វូងបម្រុងនឹងបុកទូកឱ្យលិច។ បន្ទាប់មក មេត្រីងើបក្បាលឡើង៖ "អាពពាល! តើឯងទៅណាដែរ មិនខ្លាចយើងត្របាក់ស៊ីទេអី?" ចូកចូកលើកដៃសំពះ៖ "កុំ! កុំស៊ីខ្ញុំអី រូបរាងខ្ញុំអាក្រក់ណាស់ ហើយខ្ញុំត្រូវទៅបេះថ្នាំ ដើម្បីព្យាបាលម៉ែ!" មេត្រីស្ដាប់ឮហើយ មានចិត្តអាណិត ក៏បានហៅកូនៗឱ្យជួយរុញទូក។



ទៅមុខបានបន្តិច វាក៏ជួបហ៊ីង កង្កែប និងក្អាត់កំពុងហែល ប្រលែងគ្នា រួចស្រែកសួរថា៖ ”សួស្តីបងៗ! តើភ្នំខ្ពស់នោះ ជាភ្នំថ្នាំទិព្វមែនទេ?” ពួកគេ ងក់ក្បាលជាសញ្ញា ប្រាប់ថាពិតជាភ្នំនោះមែន។ ចូកចូកក៏សុំឱ្យពួកគេជូនទៅបេះថ្នាំជួយជីវិតម្ដាយ។ ពេលនោះ ពួកគេក៏ក្លាយជាសម្លាញ់នឹងគ្នា។



ឆ្លងដៃទន្លេរួច វាក៏ដើរទៅជាមួយមិត្តភក្តិថ្មី។ ពួកគេដើរផង លោតផង ហក់ផង ស្រែកច្រៀងចេចចាចឮពេញព្រៃ។ ប៉ុន្តែចូកចូកមានទឹកមុខមិនស្រស់សោះ ព្រោះបារម្ភពីម្តាយ។



ពេលឡើងដល់ចង្កេះភ្នំ ហ៊ីង កង្កែប និងក្អាត់ហេវហត់អស់កម្លាំង។ ចូកចូកក៏សុំឱ្យត្រឡប់ទៅវិញ។ វាឱបពួកគេម្នាក់ម្ដងៗទាំងអាឡោះអាល័យ ហើយបន្តដំណើរទៅមុខទៀត។



ចូកចូកត្រេកអរខ្លាំងណាស់ លោតចុះលោតឡើង នៅពេលបេះបានស្លឹកឈើទិព្វ។ ពេលនោះ វាក៏គិតរកមធ្យោបាយត្រឡប់ទៅឱ្យបានលឿន។



រំពេចនោះ ចូកចូកឃើញថង់ជាច្រើនត្រូវខ្យល់កួចអណ្តែតឡើង
ព្រោងព្រាត។ វាលោតចាប់ថង់ចុះឡើងៗ ដើម្បីយកមកច្នៃជា
មធ្យោបាយធ្វើដំណើរ។





ក្រោយពីកែច្នៃហើយ វាលោត ឡើងទៅចុងឈើខ្ពស់ ហោះទៅ
វឹង។ ចៃដន្យ ស្រាប់តែមានភ្លៀង ធ្វើឱ្យវាធ្លាក់ចុះព្មសូរតែក្អុក!



ដំរីភ្ញាក់ព្រើត លាន់មាត់ខ្លាំងៗថា៖ ”អីយ៉ាស់! តើសត្វអីអាចម៍ដាក់ខ្នងខ្ញុំហ្នឹង?” ”ទេៗ! មិនមែនអាចម៍ទេ គឺខ្ញុំទេតើបងដំរី!” ”អូ!អាច្រមក់ទេអី! ម៉េចបានជាឯងធ្លាក់ចុះមក?” ចូកចូកបានប្រាប់តាមដំណើររឿង ហើយសុំឱ្យដំរីជួយបោះទៅលើវិញ។



ចូកចូកលោតទៅលើប្រមោយ រួចដំរីក៏គ្រវែងទៅវឹងតែម្តង។ វាលានត្រយោងហោះទៅយ៉ាងលឿន ស្រាប់តែប្រទះនឹងសត្វស្ទាំងមួយក្បាល។ បក្សីកំណាចស្រែកគំរាមថា៖ ”អាកញ្ចាញ់ចេកសម្លម ប្រញាប់ទៅណា? ឯងជាចំណីអញហើយ ហាសហា៎!”





ស្ទាំងចាប់កូនកញ្ចាញ់ចេកជាប់។ ចូកចូកលៀនអណ្ដាតភ្លែមៗដូចពស់ ហើយស្រែកអង្វរ៖ ”កុំស៊ីខ្ញុំអី! ស្លាប់ឥឡូវហើយៗ! ដោះលែងខ្ញុំទៅ ខ្ញុំប្រញាប់យកថ្នាំទៅជួយម៉ែ! បើទៅមិនទាន់ទេ ខ្ញុំលែងមានម៉ែហៅទៀតហើយ!” ស្ទាំងអាណិតពេក ក៏លះបង់បំណងចង់ស៊ី កូនកញ្ចាញ់ចេក ហើយជួយនាំវាទៅដល់ផ្ទះតែម្ដង។



ចុងក្រោយ ចូកចូកយកស្លឹកឈើទិព្វទៅលាបលើដំបៅម្ដាយ រហូតជាបានសះស្បើយដូចធម្មតាវិញ។



វាថែមទាំងអួតប្រាប់ម្ដាយក្ដែងៗថា៖ ”ម៉ែ! ម៉ែ! ឥឡូវ ខ្ញុំចេះហោះហើយ!” ម្ដាយមិនជឿ វាក៏យកឆត្រយោងចេញមក។ ម្ដាយលាន់មាត់ថា៖ ”ចូកចូកឆ្លាតណាស់ ពិតជាពូកែមែន! កូនត្រូវប្រមូលថង់ប្លាស្ទិកនិងកំប៉ុងជ័រឱ្យបានច្រើន ដើម្បីទុកកែច្នៃវត្ថុអស្ចារ្យមួយទៀត!” ”បាទម៉ែ! ខ្ញុំចង់បង្កើតយន្តហោះធំមួយដើម្បីនាំម៉ែដើរកម្សាន្តនិងអរគុណបងៗដែលបានជួយកូន!”



ម្តាយភ្ញាក់ផ្អើល ហើយសរសើរថា៖ ”អស្ចារ្យៗ! អស្ចារ្យខ្លាំងណាស់!” ចូកចូករំភើបខ្លាំងពេក លោតទៅលើចុងឈើ ហើយស្រែកថា៖ ”ជយោៗ! ខ្ញុំជិតបានទៅជួបពួកបងៗហើយ កុំភ្លេចខ្ញុំណា៎ ខ្ញុំគឺចូកចូក!”



The Asia Foundation

CONSERVATION INTERNATIONAL

ដើម្បីកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្រសួងបរិស្ថាន នៃរដ្ឋាភិបាលកម្ពុជា បានបង្កើតគោលនយោបាយមួយស្តីពីការតម្រូវឱ្យផ្សារទំនើបទាំងអស់ក្នុង ក្រុងភ្នំពេញត្រូវលក់ថង់ប្លាស្ទិក បើសិនអតិថិជនត្រូវការ (តំលៃ៤០០រៀល ក្នុងមួយថង់) ។ រដ្ឋាភិបាលកម្ពុជាក៏បានបង្កើតជាវីដេអូដើម្បីអប់រំប្រជាពលរដ្ឋពីផលប៉ះពាល់នៃប្លាស្ទិកទៅលើផែនដី និងពីវិធីកាត់បន្ថយការប្រើប្រាស់។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់៖

https://plasticfreecambodia.com/individuals/

https://www.youtube.com/watch?v=Wyt3H0XGThM&t=2s

Generously supported by SMART

## Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*កញ្ចាញ់ចេកសម្លម (The Clever Frog)*, Author: Sat Dich. Illustrator: Sorn Srey Neang. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/